**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ : ៣៦ អយក.គល.សណ

## សេចក្ដីជូនដំណឹងស្ដីពី

## ការអញ្ជើញចូលរួមដេញថ្លៃ ការសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង ០៤បន្ទប់ និងអណ្ដូងស្នប់ ០១ និងបំពាក់តុ កៅអី ក្ដារខៀន នៅសាលាបឋមសិក្សា គោជោងបក់គីរ ភូមិ គោជោងបក់គីរ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់)

ក្រសួងអប់រំ យុវជន និងកីឡា សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន (គិតទាំងសហគ្រាសឯកត្ដបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការសាងសង់អគារសិក្សាចំនួន ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង ០៤បន្ទប់ និងអណ្ដូងស្នប់ ០១ និងបំពាក់តុ កៅអី ក្ដារខៀន នៅសាលាបឋមសិក្សា គោជោងបក់គីរ ភូមិ គោជោងបក់គីរ ឃុំអំពិល ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) ។

កិច្ចលទ្ធកម្មនេះនឹងត្រូវបានធ្វើឡើង តាមរយៈវិធីសាស្ត្រការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក ក្រោមច្បាប់ និងស្របតាមបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា ដែលមានអាសយដ្ឋាន អគាររដ្ឋបាលថ្មី ( សាលាបឋមសិក្សា ចៅពញាហុក) ផ្លូវលេខ៣៨០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ ៖០២៣ ២២០ ៤១២ ,០២៣ ២២០ ៩២៧ ទូរសារ/ទូរស័ព្ទលេខ ៖ ០២៣ ២១៥ ២០២ សារអេឡិចត្រូនិច ៖ procurement@moeys.gov.kh គេហទំព័រ ៖ www.moeys.gov.kh/procurement ចាប់ពីថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ ២០១៥ តទៅរៀងរាល់ម៉ោងធ្វើការ ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ៣ និង៣០ នាទីរសៀល ថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១៦ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង៣ និង៣០ នាទីរសៀល ថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១៦ ។

ក្រុមហ៊ុន ដែលមានសម្ព័ន្ធភាពជាមួយ ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ- កាលប្បវត្តិ